# របាយការណ៍
# លទ្ធផលការងារវប្បធម៌ និងវិចិត្រសិល្បៈប្រចាំខែឧសភា ឆ្នាំ២០១៦

ៃៃៃៃៃៃ

ក្នុងរយៈពេលមួយខែកន្លងមកនេះ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដែលមានថ្នាក់ដឹកនាំ និងគ្រប់អង្គភាពថ្នាក់កណ្តាល និងថ្នាក់រាជធានី-ខេត្ត បានខិតខំប្រឹងប្រែងធ្វើការងារយ៉ាងមោះមុតជាប្រចាំ គឺធ្វើយ៉ាងណាឲ្យសម្រេចបានជាដំណាក់កាលៗ ទៅតាមផែនការសកម្មភាពការងារវប្បធម៌ និងវិចិត្រសិល្បៈឆ្នាំ២០១៦ ដែលក្រសួងបានរៀបចំឡើងដោយអនុលោមតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិក្នុងវិស័យវប្បធម៌២០១៤-២០១៨ និងគោលនយោបាយជាតិស្តីពីវិស័យវប្បធម៌។ ក្នុងការអនុវត្តផែនការសកម្មភាពនិងការងារវប្បធម៌និងវិចិត្រសិល្បៈខាងលើ ក្រសួងមានរចនាសម្ព័ន្ធដែលជាយន្តការធ្វើការងារ ហើយសម្រេចបាននូវលទ្ធផលដូចជម្រាបជូនខាងក្រោម ៖

## ១. សកម្មភាព និងលទ្ធផលការងារ ៖

### ១.១. សកម្មភាពថ្នាក់ដឹកនាំ ៖

*<u>សកម្មភាពក្នុងប្រទេស ៖</u>*

- **ថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៦** ឯកឧត្តម ថៃ នរៈសត្យា រដ្ឋលេខាធិការ ចូលរួមក្នុងពិធីសំណេះសំណាលជាមួយកម្មករ និងនិយោជិតនៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ នាឱកាសអបអរសាទរខួបលើកទី១៣០ នៃទិវាពលកម្មអន្តរជាតិ០១ ឧសភា នៅខេត្តព្រះសីហនុ
- **ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៦** លោកជំទាវរដ្ឋមន្ត្រី ចូលរួមជាកិត្តិយសក្នុងពិធីផ្សព្វផ្សាយដាក់ឲ្យប្រើប្រាស់ជាផ្លូវការ គោលនយោបាយជាតិប្រជាជន ២០១៦ -២០៣០ នៅទីស្តីការគណៈរដ្ឋមន្ត្រី
- **ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ៖**
    - លោកជំទាវរដ្ឋមន្ត្រី ចូលរួមក្នុងកម្មវិធី Grand Opening Ceremony of the Japan Foundation Asia Center នៅស្ថានទូតជប៉ុន
    - លោកជំទាវរដ្ឋមន្ត្រី ចូលរួមជាគណៈអធិបតីក្នុងពិធីសម្ពោធពិព័រណ៍មិនអចិន្ត្រៃយ៍ស្តីពី "កម្ពុជា និងសង្គ្រាមលោកលើកទី១៖ សំណល់បេតិកភណ្ឌពីសង្គ្រាមនៅបាតសមុទ្រ" នៅសារមន្ទីរជាតិ

- ឯកឧត្តម យឹម សារិទ្ធ រដ្ឋលេខាធិការ ចូលរួមជាកិត្តិយសក្នុងពិធីបុណ្យបញ្ចុះខណ្ឌសីមា ព្រះវិហារវត្តកែវមុនី ខេត្តកំពង់ចាម
- ឯកឧត្តម ស្រី សួន អនុរដ្ឋលេខាធិការ ចូលរួមកិច្ចប្រជុំធ្វើបច្ចុប្បន្នភាពការងាររបស់ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) នៅក្រសួងមហាផ្ទៃ

- **ថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៦** លោកជំទាវរដ្ឋមន្ត្រី អនុញ្ញាតជូនសមាគមសិល្បករខ្មែរ និង គណៈប្រតិភូបវរកញ្ញា Global អន្តរជាតិ ២០១៥ ចូលជួបសម្តែងការគួរសម និងពិភាក្សា ការងារ នៅទីស្តីការក្រសួង
- **ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៦ ៖**
  - លោកជំទាវរដ្ឋមន្ត្រី ទទួលជួប ឯកឧត្តម Dmitry TSVETKOV ឯកអគ្គរដ្ឋទូតសហព័ន្ធរុស្សី ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នៅទីស្តីការក្រសួង
  - ឯកឧត្តម ថៃ នរៈសត្យា រដ្ឋលេខាធិការ ចូលរួម ប្រជុំបើកតំបន់វិនិច្ឆ័យចុះបញ្ជីដីធ្លីមាន លក្ខណៈជាប្រព័ន្ធជូនប្រជាពលរដ្ឋដែលកំពុងរស់នៅតាមសហគមន៍បណ្តោះអាសន្ន ដែលជាទីតាំងដីឯកជនរបស់រដ្ឋក្នុងរាជធានីភ្នំពេញ នៅសាលារាជធានីភ្នំពេញ
- **ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៦ ៖**
  - ឯកឧត្តម សោម សុគន្ធ រដ្ឋលេខាធិការ ចូលរួមជាកិត្តិយសក្នុងពិធីប្រគល់សញ្ញាបត្រ ដល់សាកលវិទ្យាល័យ អាយអាយស៊ី នៅវិទ្យាស្ថានជាតិអប់រំ
  - ឯកឧត្តម ជុច ភឿន រដ្ឋលេខាធិការ ចូលរួមត្រួតពិនិត្យការបិទកេសវត្ថុបុរាណជើងទម្រ នៃបដិមាព្រះនាងឧមា អំពីថ្ម នៅសារមន្ទីរជាតិ
- **ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០១៦**លោកជំទាវរដ្ឋមន្ត្រី ចូលរួមក្នុងកម្មវិធី Concert of the Russian Music នៅ Russian Centre of Science and Culture
- **ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៦** ឯកឧត្តម សោម សុគន្ធ រដ្ឋលេខាធិការ ចូលរួមក្នុងកម្មវិធី Opening ceremony of the Thai Film Festival 2016 នៅផ្សារទំនើប AEON Mall
- **ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦ ៖**
  - ឯកឧត្តម ជុច ភឿន រដ្ឋលេខាធិការ ចូលរួមក្នុងកិច្ចប្រជុំលើកទី១នៃគណៈកម្មាធិការ តម្រង់ទិសដើម្បីដោះស្រាយបញ្ហាដីធ្លីនៅក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដទៃទៀត ដែលស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរអប្សរា នៅទីស្តីការគណៈរដ្ឋមន្ត្រី
  - ឯកឧត្តម ថៃ នរៈសត្យា រដ្ឋលេខាធិការ ចូលរួមក្នុងកម្មវិធី Korean National Ballet Gala នៅសាលសន្និសីទចតុម្មុខ
  - ឯកឧត្តម គង់ កន្ធារ៉ា អនុរដ្ឋលេខាធិការ ចូលរួម សិក្ខាសាលាពិគ្រោះយោបល់លើសេចក្តី ព្រាងរបាយការណ៍បឋម ស្តីពីការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការ នៅសណ្ឋាគារភ្នំពេញ
  - ឯកឧត្តម ស្រី សួន អនុរដ្ឋលេខាធិការ ចូលរួមក្នុងពិធីប្រកាសពានរង្វាន់កម្មវិធីសាលារៀន គំរូលើការជម្រុញការពាក់មួកសុវត្ថិភាព នៅមជ្ឈមណ្ឌលសហប្រតិបត្តិការ កម្ពុជា-ជប៉ុន
- **ថ្ងៃទី២១-២៥ ខែឧសភា ឆ្នាំ២០១៦** ឯកឧត្តម យឹម សារិទ្ធ រដ្ឋលេខាធិការ ដឹកនាំក្រុមជំនាញ ក្រសួងចុះទៅធ្វើពិធីដង្ហែព្រះអង្គធំអំពីថ្មភក់ ពីខេត្តសៀមរាប ទៅខេត្តរតនៈគីរី
- **ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៦** ឯកឧត្តម ថៃ នរៈសត្យា រដ្ឋលេខាធិការ ចូលរួមក្នុងពិធី ប្រគល់សញ្ញាបត្រដល់និស្សិត សាកលវិទ្យាល័យ អាស៊ីអឺរ៉ុប នៅវិទ្យាស្ថានជាតិអប់រំ

- **ថ្ងៃទី២៦-២៧ ខែឧសភា ឆ្នាំ២០១៦** លោកជំទាវ នេត្រ ភូម៉ារី អនុរដ្ឋលេខាធិការ ចូលរួមជាកិត្តិយសក្នុងកម្មវិធីតន្ត្រីបរិស្ថាន នៅខេត្តកំពង់ឆ្នាំង
- **ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៦** លោកជំទាវ នេត្រ ភូម៉ារី អនុរដ្ឋលេខាធិការ ចូលរួមសិក្ខាសាលាផ្សព្វផ្សាយព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ នៅសណ្ឋាគារអាំងទែកង់ទីណង់តាល់

*<u>សកម្មភាពក្រៅប្រទេស ៖</u>*

- **ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៦ ឯកឧត្តម សំរាំង កំសាន្ត រដ្ឋលេខាធិការ** ដឹកនាំគណៈប្រតិភូចូលរួមកិច្ចប្រជុំលើកទី១ ស្តីពីកិច្ចសហប្រតិបត្តិការវប្បធម៌កម្ពុជា -ហ្វីលីពីន ( First Philippines-Cambodia Cultural Cooperation Meeting) នៅសាធារណរដ្ឋហ្វីលីពីន
- **ថ្ងៃទី១៦-២១ ខែឧសភា ឆ្នាំ២០១៦ លោកជំទាវរដ្ឋមន្ត្រី** ដឹកនាំគណៈប្រតិភូចូលរួមកិច្ចប្រជុំកំពូលរដ្ឋមន្ត្រីវប្បធម៌អាស៊ាន-រុស្ស៊ី ( Meeting of Culture Ministers of Russia and ASEAN ) នៅសហព័ន្ធរុស្ស៊ី

## ១.២. សកម្មភាព និងលទ្ធផលការងារតាមអង្គភាព ៖

### *១.២.១ អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ៖*

*<u>នាយកដ្ឋានរដ្ឋបាលទូទៅ៖</u>*

- បានទទួលលិខិតចូលពីគ្រប់ស្ថាប័នចំនួន៥៤០ច្បាប់ និងបញ្ជូនលិខិតចេញទៅគ្រប់ស្ថាប័នចំនួន៣៣២ច្បាប់។ ទន្ទឹមនេះក៏បានតាក់តែងលិខិតរដ្ឋបាល និងលិខិតផ្សេងៗទៀតបានចំនួន២៥ច្បាប់តាមបញ្ជារបស់ថ្នាក់ដឹកនាំ
- បានរៀបចំទទួលភ្ញៀវជាតិ អន្តរជាតិ និងកម្មវិធីប្រជុំផ្សេងៗបានទាន់ពេលវេលា
- ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាលដោយបានរៀបចំ កម្លាំងសន្តិសុខ និងនគរបាលយាមកាមប្រចាំការពេលថ្ងៃ និងយប់បានល្អប្រសើរក្នុងការថែរក្សាសុវត្ថិភាពនៅទីស្តីការក្រសួង
- បានធ្វើការបែងចែកសៀវភៅរាជកិច្ចជូនថ្នាក់ដឹកនាំតាមគោលការណ៍ប្រចាំខែ
- ការិយាល័យព័ត៌មានវិទ្យាបានបន្តដំណើរការជាធម្មតាតាមផែនការកំណត់

*<u>នាយកដ្ឋានបុគ្គលិក ៖</u>*

- បានធ្វើការផ្សព្វផ្សាយអនុក្រឹត្យលេខ៥៦ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យាដល់អង្គភាពថ្នាក់រដ្ឋបាលទាំងអស់
- បានចុះផ្សព្វផ្សាយច្បាប់ទាក់ទងការងារបុគ្គលិកនៅមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តពោធិ៍សាត់
- បានធ្វើសំណើសុំនិយ័តក្របខ័ណ្ឌសម្រាប់ជ្រើសរើសក្របខ័ណ្ឌថ្មីឆ្នាំ២០១៦ ទៅក្រសួងមុខងារសាធារណៈ
- បានធ្វើសំណើសុំតម្លើងឋានន្តរស័ក្តិ ថ្នាក់ ជូនមន្ត្រីរាជការចំនួន១ .៦៦៣នាក់ ក្នុងនោះក្របខ័ណ្ឌរដ្ឋបាលចំនួន៧៧៣នាក់ និងក្របខ័ណ្ឌបច្ចេកទេសចំនួន៨៩០នាក់ ទៅក្រសួងមុខងារសាធារណៈ
- បានដកមន្ត្រីចូលនិវត្តន៍ចំនួន០៣នាក់ និងមន្ត្រីទទួលមរណភាពចំនួន០១នាក់ ចេញពីតារាងបៀវត្ស

- បានធ្វើប្រកាសជូនមន្ត្រីរាជការឲ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្សចំនួន០១នាក់ នៅមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តតាកែវ

## *នាយកដ្ឋាននីតិកម្ម ៖*

- បានចូលរួមប្រជុំត្រួតពិនិត្យចុងក្រោយប្រកាសរួមស្តីពី ការផ្តល់សេវាសាធារណៈលើវិស័យវប្បធម៌ នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានចូលរួមប្រជុំដើម្បីរៀបចំដាក់ឲ្យប្រើប្រាស់ការផ្តល់ព័ត៌មានសេវាសាធារណៈ (សេវាអាទិភាព) តាមបច្ចេកវិទ្យាទូរស័ព្ទស្មាតហ្វូន នៅក្រសួងមុខងារសាធារណៈ
- បានចូលរួមសិក្ខាសាលាស្តីពី ការផ្សព្វផ្សាយ កម្រងច្បាប់ខ្មែរពីបុរាណ នៅសណ្ឋាគារសូហ្វីតែល
- បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងរបាយការណ៍បឋមស្តីពីការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការ នៅសណ្ឋាគារភ្នំពេញ

## *នាយកដ្ឋានសម្ភារៈ និងបរិក្ខារ ៖*

- បានធ្វើតារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនឡើង-ថយចុះក្នុងឆ្នាំ២០១៥ របស់ទីស្តីការក្រសួងវប្បធម៌ និងអង្គភាពក្រៅក្រសួង
- បានធ្វើលិខិតបង្គាប់ការស្តីពីការបង្កើតគណៈកម្មការធ្វើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០១៥
- បានចុះផ្ទៀងផ្ទាត់បញ្ជីសារពើភណ្ឌ និងធ្វើតារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនឡើង-ថយចុះក្នុងឆ្នាំ២០១៥របស់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តតាកែវ កែប ព្រៃវែង ពោធិ៍សាត់ ព្រះសីហនុ កណ្តាល ស្វាយរៀង បាត់ដំបង និងប៉ៃលិន
- បានបន្តធ្វើការផ្គត់ផ្គង់សម្ភារៈការិយាល័យ និងជួសជុលសម្ភារៈការិយាល័យជូនគ្រប់បណ្តាអង្គភាព និងថ្នាក់ដឹកនាំ
- បានបញ្ចប់នីតិវិធីប្រគល់-ទទួលប្រេងឥន្ធនៈឆមាសទី១ ឆ្នាំ២០១៦ ព្រមទាំងបានបែងចែកជូនគ្រប់បណ្តាអង្គភាព និងថ្នាក់ដឹកនាំ សម្រាប់ខែមករា-មេសា
- បានលើកគម្រោងជួសជុលកែលម្អបន្ទប់អនាម័យ និងប្រព័ន្ធលូសាលាមធ្យមវិចិត្រសិល្បៈ
- បានប្រគល់-ទទួលសម្ភារៈការិយាល័យឆមាសទី១ ឆ្នាំ២០១៦

## *ការងារអង្គភាពលទ្ធកម្ម*

- បានធ្វើសំណើសុំគោលការណ៍ស្តីពីការងារថែទាំ និងជួសជុលម៉ាស៊ីនត្រជាក់គ្រប់អង្គភាព និងតបណ្តាញអគ្គិសនីថ្មីនៅទីស្តីការក្រសួង
- បានអនុវត្តការងារពិគ្រោះថ្លៃស្តីពីការងារ ៖
    - ផ្គត់ផ្គង់ភេសជ្ជៈសម្រាប់ទទួលភ្ញៀវក្នុងឆ្នាំ២០១៦
    - ធ្វើបង្គោលការពារស្ថានីយបុរាណនៅរាជធានី -ខេត្តចំនួន៥ ក្នុងឆ្នាំ២០១៦
- បានអនុវត្តការងារប្រគល់-ទទួលសម្ភារៈការិយាល័យ និងបោះពុម្ពសម្រាប់ឆមាសទី១ ឆ្នាំ២០១៦

*<u>នាយកដ្ឋានផែនការ ស្ថិតិ និងសរុប ៖</u>*

- បានរៀបចំធ្វើរបាយការណ៍ប្រចាំខែឧសភា និងបានផ្ញើគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធទៅតាមកាលកំណត់របស់រាជរដ្ឋាភិបាល
- បានបន្តរៀបចំតារាងតាមដានការអនុវត្តផែនការសកម្មភាពការងារវប្បធម៌ និងវិចិត្រសិល្បៈប្រចាំត្រីមាសទី១ និងខែមេសា ដើម្បីធានាប្រសិទ្ធភាពក្នុងការអនុវត្តផែនការឆ្នាំ២០១៦
- បានបន្តរៀបចំផែនការឆ្នាំ២០១៧

*<u>នាយកដ្ឋានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ៖</u>*

- បានប្រជុំកែសម្រួលប្រកាស ស្តីពីការបង្កើតអង្គភាពគ្រប់គ្រងសិទ្ធិរួម
- បានពិនិត្យឯកសារ និងបកប្រែអត្ថបទ ស្តីអំពីសន្ធិសញ្ញា Beijing
- បានចេញសេចក្តីជូនដំណឹងដល់សាធារណៈជនដែលមានបំណងប្តឹងជំទាស់នឹងការស្នើសុំសិទ្ធិគ្រប់គ្រងមរតកសាសន៍បទចម្រៀងចំនួន៥៧បទដែលជាស្នាដៃលោក ស៊ិន ស៊ីសាមុត
- បានចុះបញ្ជីសុំសិទ្ធិធ្វើអាជីវកម្មលើស្នាដៃគ្មានមរតកសាសន៍ចំនួន១១បទ
- បានទទួលថវិកាចំនួន៣៣០.០០០រៀល បង់ចូលថវិការដ្ឋ

*<u>នាយកដ្ឋានសហប្រតិបត្តិការវប្បធម៌អន្តរជាតិ និងកិច្ចការអាស៊ាន ៖</u>*

- បានសម្រួលបែបបទជូនថ្នាក់ដឹកនាំ មន្ត្រីជំនាញទៅចូលរួមប្រជុំ បំពេញបេសកកម្ម និងសម្តែងសិល្បៈបានចំនួន១៣លើក៖ នៅប្រទេសថៃ វៀតណាម ហ្វីលីពីន ឥណ្ឌូណេស៊ី ជប៉ុន ចិន បារាំង ស្វីស និងរុស្ស៊ី
- បានទទួលគណៈប្រតិភូសិល្បៈរបស់នាយកដ្ឋានវប្បធម៌ ខេត្ត Guangdong នៃសាធារណរដ្ឋប្រជាមានិតចិន មកសម្តែងក្នុងកម្មវិធី "China Guangdong Culture Silk Road Tour 2016" និង "China Today Arts Week in Cambodia 2016"
- ឯកឧត្តម សំរាំង កំសាន្ត រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និង ឯកឧត្តម Felipe M. De Leon, JR. ប្រធាននៃគណៈកម្មាធិការជាតិ ដើម្បីវប្បធម៌ និងសិល្បៈ (ភាគីហ្វីលីពីន)បានចុះហត្ថលេខាលើ " Executive Program for Cultural Cooperationbetween the National Commission for Culture and the Arts of the Republic of the Philippines and the Ministry of Culture and Fine Arts of the Kingdom of Cambodia for the Years 2016-2019" នៅទីក្រុងម៉ានីល នៃសាធារណរដ្ឋហ្វីលីពីន

### ១.២.២. អគ្គនាយកដ្ឋានបេតិកភណ្ឌ៖

*<u>នាយកដ្ឋានគាំពារ និងអភិរក្សសំណង់បុរាណ ៖</u>*

<u>ក.ការងារអភិរក្សដ្ឋានអង្គរ ៖</u>

- បានទទួលអ្នកស្រាវជ្រាវមកពីសាលាបារាំងចុងបូព៌ាប្រទេស និងមន្ត្រីមកពីសារមន្ទីរជាតិភ្នំពេញចូលផ្ទៀងផ្ទាត់វត្ថុសិល្បៈក្នុងឃ្លាំង

- បានចូលរួមក្នុងការថតភាពយន្តឯកសារអំពី "ប្រាសាទបុរាណនានានៅក្នុងតំបន់អង្គរ" ដោយសហការជាមួយស្ថានីយទូរទស្សន៍អាស៊ីអាគ្នេយ៍នៅក្នុងអភិរក្សដ្ឋានអង្គរ ប្រាសាទបន្ទាយក្ដី និងស្រះស្រង់
- បានតាមដានការរៀបចំវត្ថុសិល្បៈក្នុងបរិវេណអភិរក្សដ្ឋានអង្គរ
- បានផ្ទៀងផ្ទាត់បញ្ជីសារពើភណ្ឌវត្ថុសិល្បៈសម័យបារាំង ដែលស្កេនរួច ចាប់ពីលេខ N.2302-N.2394, N.2400-N.2498, N.2500-N2598, N.2602-N2698, N.2700-N2799, N.2804-N.2899, N.2900-N2990, N.3021-N3098, N.3101-N3186, N.3319-N3399 ដើម្បីត្រៀមបោះពុម្ពជាសៀវភៅ
- បានចូលរួមស្រាវជ្រាវរកឯកសារអំពីចម្លាក់គោក្នុងបរិវេណអភិរក្សដ្ឋានអង្គរ ដើម្បីកំណត់រចនាបថ
- បានចូលរួមអនុវត្តគម្រោងថែទាំ គាំពារស្ពានទ័ព ខេត្តឧត្តរមានជ័យ

**<u>ខ.ការងារស្រាវជ្រាវ និងចងក្រងឯកសារប្រវត្តិសាស្ត្រក្នុងកិច្ចការពារតំបន់ប្រាសាទ៖</u>**

បានចុះទៅពិនិត្យការដ្ឋានជួសជុលស្ពានទ័ព ខេត្តឧត្តរមានជ័យ និងប្រាសាទបាសែត ខេត្តបាត់ដំបង។

**<u>គ.ការងារគ្រប់គ្រងរមណីយដ្ឋានវប្បធម៌ ៖</u>**

បានចុះទៅធ្វើសម្រង់ប្លង់នៅប្រាសាទនគរបាជ័យ ខេត្តកំពង់ចាម។

**<u>ឃ.ការងារជួសជុលប្រាសាទ និងសំណង់បុរាណ ៖</u>**

- បានចុះពិនិត្យការដ្ឋានជួសជុលប្រាសាទបាសែត ខេត្តបាត់ដំបង ដើម្បីវិភាគល ម្អិតរកឲ្យឃើញអំពីមូលហេតុនៃការខូចខាតរបស់ប្រាសាទ និងធ្វើផែនការជួសជុលប្រាសាទឡើងវិញតាមលក្ខណៈបុរាណ
- បានអនុវត្តគម្រោងជួសជុល ៖
    - ស្ពានទ័ព ខេត្តឧត្តរមានជ័យ
    - ប្រាសាទបាសែត ខេត្តបាត់ដំបង
    - គាំពារ និងអភិរក្សប្រាសាទនាងខ្មៅ ខេត្តតាកែវ
    - គាំពារ និងអភិរក្សប្រាសាទភ្នំគ្រប់ ខេត្តកណ្ដាល
    - គាំពារ និងអភិរក្សវត្តមហាលាភ ខេត្តកំពង់ចាម

**<u>ង.ការងារគ្រប់គ្រងសំណង់ប្រវត្តិសាស្ត្រ ៖</u>**

បានចូលរួមការងារអនុវត្តគម្រោងអភិរក្ស និងជួសជុលស្ពានទ័ព ខេត្តឧត្តរមានជ័យ និងប្រាសាទបាសែត ខេត្តបាត់ដំបង។

**<u>ច.ការងារអភិរក្សតាមបណ្ដាខេត្ត៖</u>**

*អភិរក្សដ្ឋានកំពង់ធំ និង ព្រះវិហារ ៖*

បានចូលរួមការងារជួសជុលប្រាសាទភ្នំគ្រប់ ខេត្តកំពង់ចាម។

*អភិរក្សដ្ឋានបាត់ដំបង បន្ទាយមានជ័យ និង ឧត្តរមានជ័យ ៖*

- បានកាត់ដើមឈើដែលដួលរលំនៅក្នុងបរិវេណប្រាសាទបន្ទាយឆ្មារ
- បានសហការជាមួយក្រុមហ៊ុន ខាំ សាម៉េត ជួសជុលផ្លូវចូលប្រាសាទតាអ៊ឹមបានប្រវែង១០០ម៉ែត្រ

**<u>ឆ.ការងារសហប្រតិបត្តិការជាមួយអន្តរជាតិ៖</u>**

- កិច្ចសហការជាមួយអង្គការ G.H.F ក្នុងការអភិរក្ស និងជួសជុលប្រាសាទ ៖
    - o បានដឹកដែករន្ទាដែលអង្គការ បានខ្ចីពីនាយកដ្ឋាន ត្រលប់មកប្រើប្រាស់នៅការដ្ឋានជួសជុលស្ពានទំព ខេត្តឧត្តរមានជ័យ
    - o បានខ្ចីរថយន្តស្ទូចរបស់អង្គការទៅប្រើប្រាស់ នៅការដ្ឋានជួសជុលប្រាសាទបាសែត ខេត្តបាត់ដំបង
- កិច្ចសហការជាមួយអង្គការ Waseda ជួសជុលប្រាសាទសំបូរព្រៃគុក ខេត្តកំពង់ធំ ៖ បាននិងកំពុងបន្តការងារជួសជុលប្រាសាទ N1

***<u>នាយកដ្ឋានសារមន្ទីរ ៖</u>***

**<u>ក.សារមន្ទីរជាតិភ្នំពេញ៖</u>**

- បាន Back-up ទិន្នន័យនៅក្នុងប្រព័ន្ធ Database
- ជួសជុលរូបចម្លាក់បាន**១៨រូប**
- បានទទួលវត្ថុសិល្បៈចំនួន២មុខគឺ "**សសរព្រះវិហារ**" អំពីឈើ ចំនួន២ដើម ពីព្រះគ្រូវិស្សាល សៀ ភារ៉ា វត្តឧណ្ណាលោម និង "**ទេវរូបភេទស្រី**" អំពីថ្មភក់ ចំនួន១ ពីប្រជាពលរដ្ឋនៅឃុំគោកត្រប់ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល
- នាយកដ្ឋានសារមន្ទីរ បានសហការជាមួយអង្គការយូណេស្កូប្រចាំកម្ពុជា រៀបចំបើកសម្ពោធពិព័រណ៍មិនអចិន្ត្រៃយ៍ ស្តីពី "**កម្ពុជា និងសង្គ្រាមលោកលើកទី១-បេតិកភណ្ឌក្រោមទឹក**" នៅសារមន្ទីរជាតិ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ លោកជំទាវ **ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ឯកឧត្តម Marc MICHIELSEN ឯកអគ្គរដ្ឋទូតប្រទេសបែលហ្សិកប្រចាំប្រទេសថៃ កម្ពុជា ឡាវ និងភូមា និងលោកស្រី Anne LEMAISTRE តំណាងអង្គការយូណេស្កូប្រចាំនៅកម្ពុជា ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម លោកជំទាវ តំណាងអង្គទូត និងភ្ញៀវជាតិ-អន្តរជាតិ ប្រមាណ២០០នាក់
- បានទទួលភ្ញៀវឲ្យចូលទស្សនាសារមន្ទីរជាតិភ្នំពេញសរុបចំនួន **១៧.០០៦នាក់** ក្នុងនោះមានភ្ញៀវជាតិចំនួន **៣.៣១៦នាក់** ទទួលបានចំណូលថវិកាចំនួន **១.១៦០.៦០០រៀល** និង ភ្ញៀវអន្តរជាតិចំនួន**១២.៣០៣នាក់** ទទួលបានចំណូលថវិកាចំនួន **៤៣.០៦០ដុល្លា** បង់ចូលថវិការដ្ឋ និង ភ្ញៀវចូលឥតបង់ថ្លៃចំនួន **១.៣៨៧នាក់**

**<u>ខ.សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង៖</u>**

- ពិនិត្យនិងឆែកឯកសារមីក្រូហ្វីលចំនួនពីរដងក្នុងមួយខែ
- ចងក្រងនិងសង្ខេបព័ត៌មានពីឯកសារចម្លើយសារភាពជនរងគ្រោះចំនួន១៥០ឯកសារ

- ស្កេនឯកសារចម្លើយសារភាពជនរងគ្រោះចំនួន៥ឯកសារ
- ចុះបញ្ជីសារពើភណ្ឌក្នុងឃ្លាំងបានចំនួន៨០វត្ថុ
- បានទទួលភ្ញៀវជាតិ-អន្តរជាតិ ព្រះសង្ឃ សិស្ស និស្សិតចូលទស្សនាមានចំនួន**៣២.៦៣៨នាក់** ក្នុងនោះភ្ញៀវអន្តរជាតិមានចំនួន**២៣.១០៤នាក់**

**<u>គ.មណ្ឌលវត្តភ្នំ៖</u>**

បានទទួលភ្ញៀវទេសចរណ៍ជាតិ-អន្តរជាតិចូលទស្សនាមានចំនួន**២.៦៨៧នាក់** ក្នុងនោះភ្ញៀវអន្តរជាតិមានចំនួន **១.១៨៧នាក់**។

**<u>ឃ.មណ្ឌលជើងឯក៖</u>**

បានទទួលភ្ញៀវទេសចរណ៍ជាតិ-អន្តរជាតិចូលទស្សនាសរុបមានចំនួន**១៨.៨៥០នាក់** ក្នុងនោះភ្ញៀវអន្តរជាតិមានចំនួន**១៤.៤៣០នាក់**។

***<u>នាយកដ្ឋានបុរាណវត្ថុ៖</u>***

- បានបន្តបញ្ចូលទិន្នន័យវត្ថុបុរាណនៅខេត្តសៀមរាបទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យ ( Database)
- បានចុះសិក្សាស្រាវជ្រាវ និងធ្វើបញ្ជីសារពើភណ្ឌវត្ថុបុរាណតាមទីតាំងមួយចំនួនក្នុងខេត្តកំពង់ឆ្នាំង និងព្រះវិហារ
- បានផ្តល់សេវាពិនិត្យវត្ថុសិល្បៈនាំចូល-នាំចេញបានចំនួនសរុប**១.០៧៨រូប** ទទួលបានថវិកាចំនួន **៧.៣២០.០០០រៀល** បង់ចូលថវិកាជាតិ

***<u>នាយកដ្ឋានបុរាណវិទ្យា និងបុរេប្រវត្តិវិទ្យា៖</u>***

- បានចូលរួមជាគ្រូឧទ្ទេសនាម និងបង្រៀនពីជំនាញបេតិកភណ្ឌនៅនាយកដ្ឋាននគរបាលការពារបេតិកភណ្ឌ នៃក្រសួងមហាផ្ទៃ
- បានចុះទៅធ្វើការអភិរក្សអដ្ឋិធាតុជនរងគ្រោះនៅមជ្ឈមណ្ឌលឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ជើងឯក រាជធានីភ្នំពេញ
- បានបន្តចូលរួមធ្វើកំណាយស្រាវជ្រាវជាមួយរាជបណ្ឌិត្យសភាកម្ពុជា នៅស្ថានីយបុរាណភូមិមូលជើងឯក រាជធានីភ្នំពេញ

***<u>ការងារបេតិកភណ្ឌរូបីតាមមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី-ខេត្ត ៖</u>***

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានីភ្នំពេញ ៖</u>***

- បានបន្តរៀបចំថែរក្សាការពារសណ្តាប់ធ្នាប់ សោភ័ណភាព អនាម័យមណ្ឌលវត្តភ្នំ បានល្អជាប្រចាំ
- បានចុះធ្វើបច្ចុប្បន្នភាពស្ថានីយបុរាណនៅតាមសង្កាត់នីមួយៗ ក្នុងខណ្ឌចំនួន៤ រាជធានីភ្នំពេញ ដោយមានការបញ្ជាក់ពីលក្ខណៈ និងទីតាំងច្បាស់លាស់ពីចៅសង្កាត់នីមួយៗ
- បានចុះចងក្រងឯកសារពីស្ថានីយបុរាណ នៅក្នុងខណ្ឌចំនួន៦ នៅរាជធានីភ្នំពេញ
- បានចូលរួមសហការជាមួយវិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ នៃរាជបណ្ឌិត្យសភាកម្ពុជា ធ្វើកំណាយស្រាវជ្រាវពីឡកុលាលភាជន៍ នៅស្ថានីយជើងឯក

- បានសហការជាមួយនាយកដ្ឋានបុរាណវិទ្យា និងបុរេប្រវត្តិវិទ្យា និងអាជ្ញាធរពាក់ព័ន្ធ ចុះតម្លើងស្លាកប៉ាណូលើទីតាំងស្ថានីយភូមិមូលដើងឯក ដើម្បីសម្គាល់លើទីតាំងបេតិកភណ្ឌ នៅខណ្ឌដង្កោ រាជធានីភ្នំពេញ

*__មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកណ្តាល ៖__*

- បានសហការជាមួយក្រុមការងារនាយកដ្ឋានគាំពារ និងអភិរក្សសំណង់បុរាណ ចុះកាប់ឆ្ការព្រៃដែលដុះលើចេតិយព្រះអង្គច័ន្ទ នៅតំបន់ស្ទួល ភ្នំព្រះរាជទ្រព្យ បានរួចរាល់ជាស្ថាពរ
- អាជ្ញាធរស្រុកអង្គស្នួល បានចុះពិនិត្យការសាងសង់រោងសក្ការៈនៅលើទួលអង្គស្រះ ស្ថិតនៅឃុំក្រាំងម្កាក់ ដែលប្រជាពលរដ្ឋបានសាងសង់ដើម្បីប្រយោជន៍រួម ក្រុមការងារបានសម្រេចផ្អាកបណ្តោះអាសន្ន រង់ចាំស្នើសុំសម្រេចពីសមត្ថកិច្ចពាក់ព័ន្ធ
- បានសហការជាមួយអាជ្ញាធរពាក់ព័ន្ធឃុំត្បែង ឃុំព្រែករកា និងឃុំដើងកើប ចុះពិនិត្យ និងចាត់វិធានការថែរក្សាស្ថានីយបុរាណដែលកំពុងប្រឈមនឹងគ្រោះថ្នាក់
- ក្រុមជាងរបស់ក្រុមហ៊ុន ផាន អ៊ីម៉ិច បានផ្អាកការជួសជុលព្រះវិហារអដ្ឋរស្សមួយរយៈ
- ទទួលប្រាក់ពីព្រះគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស    ដែលបានឧបត្ថម្ភថ្លៃភ្លើងចំនួន១.២៥២.៨០០រៀល សម្រាប់បំភ្លឺនៅព្រះសក្យមុនីចេតីយ និងឧបត្ថម្ភថវិកាដល់ឆ្នាំចំនួន២០០.០០០រៀល

*__មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកែប ៖__*

- បានសហការជាមួយគណៈកម្មការវត្តបោសសម្អាត កាប់ឆ្ការព្រៃផ្លូវចូលរូង និងបរិវេណរមណីយដ្ឋានភ្នំសសៀរជាប្រចាំ
- បានចុះពិនិត្យស្ថានភាពទួលអង្គ "អង្គតាស៊ិន" ស្ថិតនៅឃុំអង្កោល ស្រុកដំណាក់ចង្អើរ
- បានចុះស្រាវជ្រាវសមុច្ច័យ និងវត្ថុសិល្បៈដើម្បីរៀបចំដាក់ឲ្យដំណើរការសារមន្ទីរខេត្ត

*__មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពង់ឆ្នាំង ៖__*

បានបន្តចុះស្រង់ស្ថិតិប្រាសាទ ទួលប្រាសាទ គ្រឹះប្រាសាទ ស្ថានីយបុរេប្រវត្តិ និងរមណីយដ្ឋានវប្បធម៌ប្រវត្តិសាស្ត្រ។

*__មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពង់ធំ ៖__*

- បានបណ្តុះបណ្តាលដល់សិស្សវិទ្យាល័យកំពង់ឈើទាលស្តីពីកិច្ចការពារបេតិកភណ្ឌ
- បានកាប់ល្បាស់ និងកាត់ស្មៅដែលដុះនៅលើប្រាសាទបន្ទាយស្ទោង
- បានផ្សព្វផ្សាយច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌជាតិដល់អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋនៅឃុំដូង ស្រុកប្រាសាទបល្ល័ង្គ និងឃុំសំបូរ ស្រុកប្រាសាទសំបូរ
- បានរកឃើញទួលប្រាសាទមួយកន្លែងដែលមានតួប៉មសង់ពីឥដ្ឋចំនួន០៥  ប៉ុន្តែបាក់បែកសល់តែគ្រឹះស្ថិតនៅឃុំប្រាសាទសំបូរ ស្រុកប្រាសាទសំបូរ
- បានបោសសម្អាតនៅតាមប្រាសាទនានាជាប្រចាំ
- បានចូលរួមផ្តាមសិលាចារឹកជាមួយមន្ត្រីជំនាញសារមន្ទីរជាតិ នៅសារមន្ទីរខេត្ត

- បានទទួលភ្ញៀវចូលទស្សនាសារមន្ទីរខេត្តចំនួន៧០នាក់ (អន្តរជាតិចំនួន៤៦នាក់) ប្រាសាទសំបូរព្រៃគុកចំនួន៩០៧នាក់ (អន្តរជាតិចំនួន៤០២នាក់) រមណីយដ្ឋានភ្នំសន្ទុកចំនួន១៥ .៥៩៨នាក់ (អន្តរជាតិចំនួន២៧នាក់) និងវត្តប្រាសាទចំនួន៤៩នាក់ (អន្តរជាតិចំនួន១៤នាក់)
- កិច្ចសហការជាមួយអង្គការ WASEDA ៖
    - o បានបន្តជួសជុលនៅប្រាសាទ N1

## *មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពត ៖*

- បានសហការជាមួយគ្រប់ការិយាល័យវប្បធម៌ស្រុក-ក្រុងក្នុងការការពារ និងថែរក្សាបុរាណស្ថាន និងបុរាណវត្ថុដែលត្រូវបានរក្សាទុកដោយសហគមន៍មូលដ្ឋាន និងវត្តអារាម
- បានចុះត្រួតពិនិត្យ និងណែនាំការសាងសង់សំណង់ នៅតំបន់ការពារប្រាសាទភ្នំឈ្លោក នៅស្រុកទឹកឈូ
- បន្តត្រួតពិនិត្យ ចងក្រងឯកសារប្រវត្តិវត្ថុបុរាណក្នុងសារមន្ទីរ

## *មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តតាកែវ ៖*

- បានសហការជាមួយនាយកដ្ឋានបុរាណវិទ្យា អាជ្ញាធរស្រុកត្រាំកក់ និងសាលាខេត្តតាកែវ បញ្ជូនអដ្ឋិធាតុនៅមណ្ឌលឧក្រិដ្ឋកម្មក្រាំងតាចាន់ ឃុំគុស ទៅធ្វើការអភិរក្សនៅមណ្ឌលឧក្រិដ្ឋកម្មជើងឯក ដែលមានលលាដ៍ក្បាលចំនួន១.៨០៨ និងបំណែកគ្រោងឆ្អឹងមួយចំនួនទៀត
- បានសហការជាមួយមន្ត្រីជំនាញក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងអាជ្ញាធរពាក់ព័ន្ធ ចុះបោះបង្គោលដែនការពារប្រាសាទភ្នំជីសូរ្យបានចំនួន១៤បង្គោល
- បានថែរក្សាវត្ថុបុរាណដែលមាននៅក្នុងសារមន្ទីរខេត្ត និងសារមន្ទីរស្រុកអង្គរបុរី
- បានទទួលភ្ញៀវចូលទស្សនាសារមន្ទីរខេត្តចំនួន២២នាក់ (អន្តរជាតិចំនួន០២នាក់) និងសារមន្ទីរស្រុកអង្គរបុរីចំនួន៤៣៤នាក់ (អន្តរជាតិចំនួន១២នាក់)

## *មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តបន្ទាយមានជ័យ ៖*

- បានទទួលវត្ថុបុរាណពីប្រជាពលរដ្ឋចំនួន៤០ដុំ និងបំណែកមួយចំនួនទៀត
- បានថែរក្សា និងត្រួសត្រាយព្រៃសម្អាតនៅប្រាសាទបន្ទាយឆ្មារ
- បានទទួលភ្ញៀវចូលទស្សនាប្រាសាទបន្ទាយឆ្មារចំនួន៥២៣នាក់ (ភ្ញៀវអន្តរជាតិ៨៨នាក់)

## *មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តបាត់ដំបង ៖*

- បានចុះដោះស្រាយទំនាស់ដីនៅទួលអន្លក់ ស្ថិតនៅស្រុកបវេល
- បានចុះទៅកំណត់ទួលបុរាណបានចំនួន៥ទួលគឺ ទួលអ្នកតាមួយ ទួលអ្នកតាពីរ ទួលចាស់ ទួលបឹងថ្ម និងទួលបឹងក្រោល
- បានទទួលវត្ថុបុរាណចំនួន៥គឺ "ដងខ្លួនទេវរូបភេទប្រុស" កំពស់៨០ស .ម បាក់ជាបួនបំណែក "ដងខ្លួនទេវរូបភេទប្រុស" កំពស់៣១ស .ម បាក់ជាពីរបំណែក "ដងខ្លួនទេវរូបភេទប្រុស" កំពស់១៥ស.មមួយកំណាត់ "ជើងទេវរូបភេទស្រី" កំពស់១៩ស .ម មួយកំណាត់ និង "ដងខ្លួនទេវរូបភេទប្រុសអង្គុយ" កំពស់២៣ស.ម បាក់ជាពីរបំណែក មកពីប្រាសាទបាសែត ដែលបានរកឃើញដោយក្រុមការងារជួសជុលប្រាសាទបាសែត នៃនាយកដ្ឋានគាំពារ និងអភិរក្សសំណង់បុរាណ និងបានចុះបញ្ជីសារពើភណ្ឌ

- បានចុះផ្ទៀងផ្ទាត់ប្លង់ទួលបុរាណចំនួន៤ នៅឃុំភ្នំសំពៅ ស្រុកបាណន់
- បានត្រួតពិនិត្យវត្ថុសិល្បៈចំនួន០១រូប "ព្រះឥសូររាំលើមនុស្សតឿដេកផ្កាប់មុខ" ធ្វើពីលោហៈ ដែលមានកំពស់៣៨.៥ស.ម និងទទឹង៣១.៥ស.ម
- បានទទួលភ្ញៀវចូលទស្សនាសារមន្ទីរខេត្តសរុបចំនួន២២នាក់ (អន្តរជាតិចំនួន៥នាក់)

## *មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តពោធិ៍សាត់ ៖*

- បានចុះទៅស្រាវជ្រាវរឿងដីធ្លីដែលប្រជាពលរដ្ឋនាំគ្នារុករានព្រៃយកដីនៅជុំវិញល្អាង១២ ស្ថិតនៅឃុំក្រពើពីរ ស្រុកវាលវែង
- បានចុះពិនិត្យបង្គោលព្រំខាងជើង និងខាងកើត នៅស្ថានីយថ្មបាយក្រៀមដែលត្រូវបានគ្រឿងចក្ររុញដីប៉ះបណ្តាលឲ្យបាក់រលំ
- បានចុះសិក្សាស្រាវជ្រាវថ្មខ្មៅនៅកណ្តាលបឹងទន្លេសាប ក្នុងស្រុកកំពង់សំណរ និងបានធ្វើការសន្និដ្ឋានថាជាថ្មបុរាណ
- បានចុះពិនិត្យ និងសំណូមពរទៅអធិការវត្តហ្លួង រក្សាទុកវត្ថុបុរាណមួយចំនួនដូចជាផ្តិល ឆ្នាំងល្វា ឆ្នាំងស្ពាន់រក្សាទុកចុះបញ្ជីជាសម្បត្តិក្រៅឃ្លាំងក្នុងវត្ត

## *មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តព្រៃវែង ៖*

- បានរៀបចំតដ្ឋកន្សែងពីផ្លូវអាស្រមលោកយាយ ទៅដល់អាស្រមលោកតាខ្លោងទ្វារចំនួន២៧០ម៉ែត្រការ៉េ ដោយប្រើប្រាស់ថវិកាសប្បុរសជន
- បានទទួលភ្ញៀវចូលទស្សនាសារមន្ទីរខេត្តចំនួន៧នាក់

## *មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តព្រះវិហារ ៖*

បានត្រួសត្រាយព្រៃសម្អាតតាមប្រាសាទបុរាណចំនួន២២.៣០០ម៉ែត្រការ៉េ។

## *មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តមណ្ឌលគីរី ៖*

បានចុះប្រមូលទិន្នន័យ និងស្រង់ស្ថិតិបេតិកភណ្ឌវប្បធម៌ដែលមាននៅក្នុងខេត្ត។

## *មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តរតនគីរី ៖*

- បានចុះត្រួតពិនិត្យ និងធ្វើការហាមឃាត់ប្រជាពលរដ្ឋ ចូលកាប់រានព្រៃឈើនៅតំបន់គ្រឹះប្រាសាទព្រះពុទ្ធ នៅស្រុកវើនសៃ
- បានចុះត្រួតពិនិត្យការកាប់រានដីព្រៃនៅតំបន់អភិរក្សភ្នំយក្សពើង នៅស្រុកបរកែវ

## *មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តសៀមរាប ៖*

- បានចុះពិនិត្យមើលប្រជាពលរដ្ឋជីកដីធ្វើអាងត្រពាំងរបស់គេឃើញព្រះសិរៈចំនួន០១ព្រះអង្គ ធ្វើពីស្ពាន់ មានកំពស់០,៣១ម៉ែត្រ ទម្ងន់១,៧គីឡូក្រាម ស្ថិតនៅឃុំបាគង ស្រុកប្រាសាទបាគង និងបានយកមករក្សាទុកនៅមន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្ត
- បានសហការជាមួយអាជ្ញាធរមូលដ្ឋានស្រុក ចុះត្រួតពិនិត្យវត្ថុបុរាណទេវរូបស្រី០១ព្រះអង្គ ធ្វើពីថ្មភក់ មានតែខ្លួន អត់ព្រះកេស អត់ជើង មានកំពស់០,៣៣ម និងទទឹង០,១៤ម ដែលត្រូវបាន

ប្រជាពលរដ្ឋប្រទះឃើញនៅបាតត្រពាំងបុរាណស្ថិតនៅឃុំគ្គីរុន ស្រុកពួក បច្ចុប្បន្នអាជ្ញាធរអប្សរា បានយកទៅរក្សាទុកនៅសារមន្ទីព្រះនរោត្តមសីហនុ អង្គរ

- បានសហការជាមួយក្រុមការងារចម្រុះសាលាស្រុកក្រឡាញ់ចុះទប់ស្កាត់ក្រុមហ៊ុនមួយជីកដីធ្វើប្រឡាយ ប៉ះពាល់ជើងប្រាសាទព្រៃល្បៀង ស្ថិតនៅឃុំស្នួល ស្រុកក្រឡាញ់ ជាលទ្ធផលខាងក្រុមហ៊ុនបានយល់ព្រមលុបប្រឡាយឲ្យដូចដើមវិញ
- បានសហការជាមួយអាជ្ញាធរស្រុកស្ទូងនិគមចុះត្រួតពិនិត្យនិងធ្វើកោសល្យវិច្ច័យវត្ថុបុរាណមួយដុំធ្វើអំពីថ្មភក់ មិនទាន់ឆ្លាក់រូបដែលមានកំពស់៨០ស.ម និងទទឹង៥៣ស.ម បានយកមករក្សាទុកនៅមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តជាបណ្ដោះអាសន្ន
- ទទួលឲ្យភ្ញៀវចូលទស្សនាសារមន្ទីរវត្តរាជបូព៌ចំនួន១០នាក់ (ភ្ញៀវអន្តរជាតិចំនួន១០នាក់) និងមណ្ឌលឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ចំនួន៨៦០នាក់ (ភ្ញៀវអន្តរជាតិចំនួន៨៥០នាក់)

*__មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តស្ទឹងត្រែង ៖__*

- បានធ្វើបញ្ជីសារពើភណ្ឌស្ដីពីស្ថានីយបុរាណ និងទួលបុរាណដែលបានរកឃើញទាំងថ្មីទាំងចាស់ មានស្ថានីយចំនួន៦៨ស្ថានីយ
- បានចុះត្រួតពិនិត្យនៅទួលប្រាសាទគូរដែលត្រូវបានគេឈូសឆាយធ្វើផ្លូវចូល ឃើញថាពុំមានការប៉ះពាល់ដល់ទួលប្រាសាទឡើយ

*__មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តស្វាយរៀង ៖__*

- បានចុះត្រួតពិនិត្យទួលបុរាណ និងប្រាសាទបុរាណចំនួន០៦លើក
- បានចុះសហការជាមួយអាជ្ញាធរដែនដីធ្វើប្លង់ទួលបុរាណចំនួន០៥ប្លង់
- បានផ្សព្វផ្សាយច្បាប់ស្ដីពីកិច្ចការពារបេតិកភណ្ឌចំនួន០១លើក
- បានចុះពិនិត្យវត្ថុបុរាណតាមទីសាធារណៈចំនួន០៣លើក

*__មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តឧត្តរមានជ័យ ៖__*

- បានចុះពិនិត្យ និងហាមឃាត់ប្រជាពលរដ្ឋដែលបានទន្ទ្រានយកដីលើទួលប្រាសាទតាចាន់មកធ្វើចំការដំឡូង នៅក្រុងសំរោង
- បានចុះកំណត់ព្រំ និងបោះបង្គោលទួលប្រាសាទតាចាន់ និងទួលប្រាសាទភ្នំដី នៅក្រុងសំរោង
- បានចុះត្រួតពិនិត្យ ស្រាវជ្រាវ និងរុករកការជីកកកាយលើទួលប្រាសាទបុរាណស្ថិតនៅស្រុកត្រពាំងប្រាសាទ
- បានចុះពិនិត្យប្រាសាទល្បើកដែលរងគ្រោះថ្នាក់ពីធម្មជាតិ ដើមឈើបាក់រលំ និងត្រៀមកាប់ឆ្ការ ព្រៃសម្អាត
- បានសហការជួសជុលស្ពានទិព្វ ឬស្ពានទ័ពជាមួយមន្ត្រីជំនាញរបស់នាយកដ្ឋានគាំពារ និងអភិរក្សសំណង់បុរាណ

**១.២.៣. អគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ ៖**

*__នាយកដ្ឋានអភិវឌ្ឍវប្បធម៌ ៖__*

- បានបន្តទំនាក់ទំនងជាមួយក្រសួងមហាផ្ទៃ ដើម្បីស្នើសុំស្ថិតិអង្គការ សមាគមក្រៅរដ្ឋាភិបាល ប្រចាំឆ្នាំ២០១៤-២០១៦
- បានសុំគោលការណ៍ចុះសិក្សាស្រាវជ្រាវអំពីស្ថិតិ និងអត្តសញ្ញាណរបស់បងប្អូនជនជាតិភាគតិច នៅខេត្តរតនគីរី
- បានបន្តរៀបចំសារមន្ទីរខ្លែងខ្មែរ ដើម្បីបើកជូនមហាជនចូលទស្សនា និងសិក្សាស្រាវជ្រាវ

***<u>នាយកដ្ឋានសិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌ ៖</u>***

- ថតវីដេអូឯកសារពីសកម្មភាពថ្នាក់ដឹកនាំ និងការងារអង្គភាពចំណុះក្រសួង បាន១ចំណងជើង
- បានកំពុងតម្លើងវីដេអូសិល្បៈយុវជនបាន៣៨ចំណងជើង ក្នុងនោះមានរបាំ ល្ខោនអប់រំ និងយីកេ
- បានបញ្ចប់ការតម្លើងឯកសារទិវាវប្បធម៌ជាតិ ៣មីនា លើកទី១៨ ឆ្នាំ២០១៦
- បានផលិតនាទីវប្បធម៌ចំនួន៤លេខ សម្រាប់ចាក់ផ្សាយខែឧសភា ឆ្នាំ២០១៦
- បាន Post នាទីវប្បធម៌ចូលទៅក្នុង YouTube ចំនួន ៤លេខ
- បាន Post ចម្រៀងខារ៉ាអូខេ បណ្តាំឪពុក និង បណ្តាំម្តាយ ចូលក្នុង YouTube និង Facebook
- បានដាក់បញ្ចូលសារអប់រំប្រឆាំងគ្រឿងញៀន និងប្រឆាំងអំពើពុករលួយទៅក្នុងផលិតផល ចម្រៀងកាយវិការ ខារ៉ាអូខេបានចំនួន១០.០៤៤ថាស
- បានទទួល និងផ្តល់ការអនុញ្ញាតថតភាពយន្តឯកសារ និងទូរទស្សន៍បរទេសបាន៣ចំណងជើង
- បានផ្តល់អាជ្ញាប័ណ្ណថ្មីធ្វើអាជីវកម្មភាពយន្ត-វីដេអូបាន៤ច្បាប់
- បានចុះបញ្ជីសុំផលិតវីដេអូខារ៉ាអូខេខ្មែរបាន៤លេខ វីដេអូរឿងខ្មែរ(០១ដុំចប់)បាន១ចំណងជើង
- បានអនុញ្ញាតច្បាប់ថតវីដេអូខារ៉ាអូខេខ្មែរបាន២៣ចំណងជើង ស្ប៉តខ្លីៗបាន០១ចំណងជើង
- បានផ្តល់ទិដ្ឋាការឲ្យធ្វើអាជីវកម្មដល់វីដេអូខារ៉ាអូខេខ្មែរបាន២លេខ វីដេអូខ្មែរ(០១ដុំចប់)បាន៣ ចំណងជើង
- បានផ្តល់ទិដ្ឋាការឲ្យធ្វើអាជីវកម្មដល់វីដេអូរឿងបរទេស (ភាយ) បាន១២ ចំណងជើង និងចុះបញ្ជីកាសែតនាំចូលពីបរទេសបាន១៥ចំណងជើង
- បានទទួលចំណូលពីការផ្តល់សេវាកម្មភាពយន្ត-វីដេអូ សរុបចំនួន**១២.៩២០.០០០រៀល** បង់ចូលថវិការដ្ឋ

***<u>នាយកដ្ឋានសិល្បៈទស្សនីយភាព៖</u>***

- បានប្រគំតន្ត្រី និងសម្តែងសិល្បៈទាំងមហាជន និងអាជីព សរុបចំនួន២២៣លើក ក្នុងនោះនាយកដ្ឋានសិល្បៈសម្តែងក្នុងស្រុកបាន៧លើក និងនៅក្រៅប្រទេសបាន០១លើក
- ក្រុមសិល្បៈបន្តហាត់សម និងតម្លើងស្នាដៃសិល្បៈសម្រាប់សម្តែងក្នុងស្រុក និងក្រៅប្រទេស

***<u>នាយកដ្ឋានសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម ៖</u>***

- បានចូលរួមសិក្ខាសាលាស្តីពី ASEAN MOTIF នៅសាធារណរដ្ឋឥណ្ឌូនេស៊ី
- បានចូលរួមកម្មវិធី A GROUP EXHIBITION OF ASEAN CHINA ACADEMIES OF Fine Arts (GEACAFA) នៅសាធារណរដ្ឋប្រជាមានិតចិន

***<u>នាយកដ្ឋានសៀវភៅ និងការអាន ៖</u>***

កំពុងបន្តនិពន្ធអត្ថបទទស្សនាវដ្តីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

***បណ្ណាល័យជាតិ៖**

- បានទទួលភ្ញៀវជាតិ-អន្តរជាតិចូលអានមានចំនួន ៥២៥នាក់
- បានទទួលសៀវភៅពីស្ថាប័ននានា និងអង្គការក្រៅរដ្ឋាភិបាល (សៀវភៅគ្រប់ភាសា) ចំនួន ១០១ក្បាល
- អ្នកសិក្សាស្រាវជ្រាវបានខ្ចីសៀវភៅយកទៅអានមានចំនួន៧៦ក្បាល
- បានទទួលទិនានុប្បវត្តិបាន១៦៩ច្បាប់ ទស្សនាវដ្តីផ្សេងៗនិងព្រឹត្តិប័ត្របរទេសចំនួន១៧៧ក្បាល
- បានចែកលេខ ISBN ដល់អ្នកបោះពុម្ពចំនួន៩៧លេខ
- បានដាក់ក្របសៀវភៅចាស់បាន១១៣ក្បាល បិទកូដសៀវភៅបាន១៩៦ក្បាល ស្កេនសៀវភៅបាន៣៨ក្បាល និងតម្កល់សៀវភៅ និងទស្សនាវដ្តីបាន២៧ចំណងជើង
- បញ្ចូលកាតាឡុកទស្សនាវដ្តីបាន៩៧ក្បាល
- ធ្វើកាតាឡុកសៀវភៅគ្រប់ប្រភេទ និងទស្សនាវដ្តីជាភាសាខ្មែរ-បរទេសបាន២១៨ក្បាល

***<u>ការងារបេតកភណ្ឌអរូបីតាមមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី-ខេត្ត៖</u>***

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានីភ្នំពេញ៖</u>***

- បានចុះស្រង់ស្ថិតិភ្លេងពិណពាទ្យនៅតាមវត្ត ក្នុងខណ្ឌទាំង១២ រាជធានីភ្នំពេញ
- បានសហការជាមួយសាលាសង្កាត់បឹងសាឡាង ចុះធ្វើកំណត់ហេតុ ណែនាំម្ចាស់អាជីវកម្មឆ្លាក់ត្រា និងដាក់ស្លាកយីហោនៅលើចិញ្ចើមផ្លូវ
- បានចុះត្រួតពិនិត្យ និងផ្សព្វផ្សាយតារាងសេវាកម្មច្រកចេញចូលតែមួយពីសេវាកម្មលើកស្លាកយីហោផ្សព្វផ្សាយពាណិជ្ជកម្ម ជាមួយមន្ត្រីការិយាល័យច្រកចេញចូលតែមួយខណ្ឌទួលគោក
- បានត្រួតពិនិត្យកន្លែងលក់កាហ្វេបញ្ចាំងវីដេអូបាន១៣ទីតាំង ទីតាំងជួល -លក់ថាសបាន១១ទីតាំង រោងភាពយន្តបាន២ទីតាំង
- បានសហការជាមួយក្រុមការងារខណ្ឌទួលគោក និងខណ្ឌដូនពេញ ចុះចាប់អាជីវកម្មហ្គេមចំនួន ០៣ទីតាំង និងដកហូតទូហ្គេមបាន១០ទូ
- បានសហការជាមួយគណៈបញ្ជាការឯកភាពខណ្ឌមានជ័យ រៀបចំពិធីវាយកម្ទេចទូហ្គេមបាញ់ត្រីចំនួន៨ទូ ដែលដកហូតបាន
- បានអញ្ជើញម្ចាស់ទីតាំងអ៊ិនធើណេតចំនួន១ទីតាំងក្នុងខណ្ឌមានជ័យឲ្យបញ្ឈប់ និងរើទីតាំងចេញព្រោះបង្កការរំខានដល់ប្រជាពលរដ្ឋជិតខាង
- បានចុះជម្រុញអាជីវករឲ្យមកធ្វើច្បាប់ពាក់ព័ន្ធវិស័យវប្បធម៌នៅការិយាល័យច្រកចេញចូលតែមួយ

***<u>មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកណ្តាល៖</u>***

- បានសហការជាមួយអាជ្ញាធរឃុំវិហារលួង និងឃុំផ្សារដែក ចុះពិនិត្យអាជីវកម្មភាពយន្ត -វីដេអូចំនួន៦កន្លែង និងបានណែនាំអាជីវករឲ្យអនុវត្តតាមគោលការណ៍ និងស្នើសុំច្បាប់អនុញ្ញាតប្រកបអាជីវកម្មឲ្យបានត្រឹមត្រូវតាមប្រកាសអន្តរក្រសួង
- ការិយាល័យច្រកចេញចូលតែមួយក្រុងតាខ្មៅ បានផ្តល់ច្បាប់សេវាកម្មលើវិស័យវប្បធម៌ និងវិចិត្រសិល្បៈចំនួន១៣ច្បាប់

### ***មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកែប ៖***

- បានចុះត្រួតពិនិត្យ ណែនាំការបញ្ចាំង និងកន្លែងជួល -លក់ថាស ឲ្យគោរពតាមគោលការណ៍ណែនាំរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានចុះស្រង់ទិន្នន័យ និងសម្ភាសអ្នកលក់វត្ថុអនុស្សាវរីយ៍អំពីសំបកខ្យង នៅក្រុងកែប

### ***មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពង់ឆ្នាំង ៖***

បានបន្តចុះត្រួតពិនិត្យ និងស្រង់ស្ថិតិសិល្បៈទស្សនីយភាព សិល្បៈសូនរូប សិល្បៈភាពយន្ត និងអភិវឌ្ឍវប្បធម៌។

### ***មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពង់ធំ ៖***

- បានបង្ហាត់សិល្បៈដល់សិស្សថ្នាលរៀងរាល់ថ្ងៃអាទិត្យ
- បានអញ្ជើញអាជីវករពាក់ព័ន្ធវិស័យភាពយន្តមកប្រជុំផ្សព្វផ្សាយប្រកាសអន្តរក្រសួងលេខ ៣៨៥៦ ប្រក និងប្រកាសលេខ១៥០-១៥១ ប្រក
- បានជម្រុញដល់មន្ត្រីតាមបណ្តាស្រុកស្រង់ទិន្នន័យ សិល្បៈសូនរូប និងសិប្បកម្ម នៅក្រុងស្ទឹងសែន
- បានចុះផ្សព្វផ្សាយអនុក្រឹត្យលេខ៦៨ អនក្រ.បក ប្រកាសអន្តរក្រសួងលេខ៣៨៥៦ ប្រក ប្រកាសរួមលេខ៩៨៧ សហវ .ប្រក និងពង្រឹងច្បាប់ដល់អាជីវករកាត់សក់ អ៊ុតសក់ សម្អាងការ ថតរូប គ្រឿងបំពងសម្លេង ផ្ទាំងផ្សាយពាណិជ្ជកម្ម នៅស្រុកប្រាសាទបល្ល័ង្គ
- បានពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពស្ថិតិជនជាតិដើមភាគតិច ដែលមាននៅស្រុកប្រាសាទបល្ល័ង្គ និងស្រុកសណ្តាន់
- បានសហការជាមួយក្រុងស្ទឹងសែន ចុះកែលម្អស្លាកយីហោស្រាបៀរអង្គរបានចំនួន២ស្លាក

### ***មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពត ៖***

- បានអនុវត្តកម្មវិធីវិក្រឹត្យការបច្ចេកទេសភ្លេងពិណពាទ្យ បាសាក់ និងមហោរីប្រចាំសប្តាហ៍
- បានផ្សព្វផ្សាយទូលាយសេចក្តីជូនដំណឹងរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈលេខ៤២សជណ ចុះថ្ងៃទី២៩ មីនា ២០១៦ ស្តីពីការរៀបចំមហោស្រពសិល្បៈកំណាព្យ និងចម្រៀងខ្មែរជាសកល លើកទី៤ ឆ្នាំ២០១៦
- បានសហការជាមួយគ្រប់ការិយាល័យវប្បធម៌ និងវិចិត្រសិល្បៈស្រុក-ក្រុង ចុះត្រួតពិនិត្យទិដ្ឋាការលើថាសគ្រប់ប្រភេទ
- បានចុះផ្សព្វផ្សាយ និងណែនាំអាជីវកម្មសូនរូប និងសិប្បកម្ម នៅក្រុងកំពត
- បានចុះត្រួតពិនិត្យ និងណែនាំការដាក់តាំង ស្លាកយីហោនៅក្រុងកំពត

### ***មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តតាកែវ ៖***

- បានចុះពិនិត្យកន្លែងជួល-លក់ថាស នៅផ្សារតាកែវ ក្រុងដូនកែវ រកឃើញថាសគ្មានបិទទិដ្ឋាការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈចំនួន៥.២១៥បន្ទះ និងបានណែនាំដល់អាជីវករត្រូវជួល-លក់ ឬបញ្ចាំងវីដេអូត្រូវមានបិទទិដ្ឋាការរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានចុះផ្សព្វផ្សាយអប់រំសីលធម៌សង្គម នៅអនុវិទ្យាល័យ ហ៊ុន សែន អង្គក្រូច និងអនុវិទ្យាល័យគោកពោធិ៍ ស្រុកបុរីជលសារ

***មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តបន្ទាយមានជ័យ ៖***

- បានដឹកនាំក្រុមសិល្បៈទៅចូលរួមសម្តែងសិល្បៈនៅប្រទេសថៃចំនួន០១លើក
- បានចុះត្រួតពិនិត្យវត្ថុសិល្បៈចម្លាក់ថ្មចំនួន២រូប ដែលនាំចេញទៅខេត្តតាកែវ

***មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តបាត់ដំបង ៖***

- បានចុះពិនិត្យការចាក់បញ្ចាំងវីដេអូតាមហាងកាហ្វេ និងចុះផ្សព្វផ្សាយដល់អាជីវករឲ្យមកធ្វើច្បាប់អាជីវកម្មបន្ត
- បានបន្តចុះពិនិត្យនៅតាមកន្លែងសិប្បកម្មចម្លាក់ និងបន្តធ្វើច្បាប់អាជីវកម្ម
- បណ្ណាល័យខេត្ត បានបើកទ្វារជូនសាធារណជនចូលអានសៀវភៅរៀងរាល់ថ្ងៃ លើកលែងថ្ងៃឈប់សម្រាក
- បានចុះជម្រុញអាជីវករឲ្យមកធ្វើច្បាប់អាជីវកម្មលើវិស័យវប្បធម៌បន្តនៅច្រកចេញចូលតែមួយស្រុកបវេល
- ការិយាល័យច្រកចេញចូលតែមួយក្រុងបាត់ដំបង បានចេញលិខិតអនុញ្ញាតប្រកបអាជីវកម្មលើវិស័យវប្បធម៌ និងវិចិត្រសិល្បៈបាន១១ច្បាប់ និងនៅស្រុកបវេល បានចំនួន២ច្បាប់

***មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តពោធិ៍សាត់ ៖***

- បានចុះកែសម្រួលក្រុមសិល្បៈកិច្ចសន្យានៅវត្តបាកានរៀងរាល់ថ្ងៃសុក្រ និងថ្ងៃសៅរ៍
- បានចុះត្រួតពិនិត្យក្រុមសិល្បៈមហាជនវត្តពោធិ៍សុវណ្ណរង្សី
- បានចុះពិនិត្យអាជីវកម្មជួល-លក់ថាសដែលគ្មានទិដ្ឋាការនៅស្រុកក្រគរ និងស្រុកបាកាន
- បានចុះតាមដានការចាក់បញ្ចាំងវីដេអូអាសអាភាសតាមហាងកាហ្វេ នៅក្រុងពោធិ៍សាត់
- បានចុះត្រួតពិនិត្យវត្ថុសិល្បៈចម្លាក់ នៅសង្កាត់បន្ទាយដី
- ការិយាល័យច្រកចេញចូលតែមួយក្រុងពោធិ៍សាត់ បានចេញលិខិតអនុញ្ញាតប្រកបអាជីវកម្មលើវិស័យវប្បធម៌ និងវិចិត្រសិល្បៈបាន០២ច្បាប់

***មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តព្រៃវែង ៖***

- បានផ្សព្វផ្សាយសេចក្តីជូនដំណឹង ស្តីពីការរៀបចំបើកមហោស្រពប្រឡងចម្រៀងខ្មែរជាសាកលឆ្នាំ២០១៦ នៅថ្នាក់ខេត្ត
- បានចុះពិនិត្យអាជីវកម្មជួល-លក់ថាសចំនួន០២កន្លែង និងណែនាំដល់អាជីវករជួល -លក់ថាសត្រូវមានទិដ្ឋាការពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈនៅស្រុកស៊ីធរកណ្តាល និងស្រុកមេសាង
- បានចុះពិនិត្យសិប្បកម្មពុម្ពស៊ីម៉ងត៍ និងស្រង់ស្ថិតិសិប្បកម្មគ្រប់ប្រភេទប្រចាំឆ្នាំ២០១៦
- បានចុះពិនិត្យការដាក់តាំងស្លាកយីហោគ្រប់ប្រភេទនៅស្រុកកំចាយមារ

***មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តព្រះវិហារ ៖***

- បានចុះត្រួតពិនិត្យ និងធ្វើច្បាប់អាជីវកម្មដល់អាជីវករជួល-លក់ថាសនៅស្រុកជ័យសែន
- បានចុះស្រង់ស្ថិតិស្លាកយីហោនៅស្រុកជ័យសែន
- ការិយាល័យច្រកចេញចូលតែមួយក្រុងព្រះវិហារ បានចេញលិខិតអនុញ្ញាតប្រកបអាជីវកម្មលើវិស័យវប្បធម៌ និងវិចិត្រសិល្បៈបាន០២ច្បាប់

## *មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តមណ្ឌលគីរី ៖*

- បានរៀបចំឯកសារក្បាច់ចម្លាក់ រចនាបថខ្មែរដើម្បីផ្សព្វផ្សាយដល់ម្ចាស់សិប្បកម្ម និងជាងចម្លាក់
- បានបញ្ចប់ការសរសេរ និងចងក្រងប្រភេទមុខម្ហូបជនជាតិដើមភាគតិចព្នងបានចំនួន៨មុខម្ហូប
- បានចុះពិនិត្យ និងថែរក្សាអាស្រមទាំងបីនៅលើ មជ្ឈមណ្ឌលវប្បធម៌ជនជាតិនៅភ្នំដោះក្រមុំ សម្រាប់ភ្ញៀវទេសចរណ៍មកលេងកំសាន្ត

## *មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តរតនគីរី ៖*

- បានចុះត្រួតពិនិត្យការហ្វឹកហាត់របស់ក្រុមសិល្បៈមហាជនភូមិតងណាងឡិៈរៀងរាល់សប្ដាហ៍
- បានចុះស្រង់ស្ថិតិមរតកមនុស្សរស់នៅស្រុកអូរជុំ ដែលទាក់ទងនឹងសិប្បកម្មតម្បាញ និងទាក់ទងរបៀបធ្វើស្រាពាង របស់បងប្អូនជនជាតិគ្រឹង
- បានបង្ហាត់របាំជូនពរ និងរបាំគោះត្រឡោកដល់សិស្សរៀងរាល់ម៉ោងធ្វើការ
- បានចុះត្រួតពិនិត្យកន្លែងជួល-លក់ថាសខុសច្បាប់ចំនួន៤ទីតាំង ដកហូតបានថាសចំនួន៦៩៧បន្ទះ នៅស្រុកវ៉ឺនសៃ
- បានចុះត្រួតពិនិត្យកន្លែងចាក់បញ្ចាំងទូរទស្សន៍ខ្សែកាប ការចាក់បញ្ចាំងតាមហាងកាហ្វេនៅ និងការបញ្ចាំងខ្សែភាពយន្តខ្នាតធំ ចំនួន១រឿង ក្រុងបានលុង
- បានចុះត្រួតពិនិត្យកន្លែងលក់វត្ថុអនុស្សាវរីយ៍នៅក្រុងបានលុង
- បានចុះត្រួតពិនិត្យសិប្បកម្មតម្បាញនៅសង្កាត់យក្សឡោម

## *មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តសៀមរាប ៖*

- បានចុះណែនាំ និងត្រួតពិនិត្យបទល្មើសភាពយន្ត-វីដេអូដល់អាជីវករ (ការផលិត ការចាក់បញ្ចាំង ការជួល-លក់ថាសអាសអាភាស និងគ្មានទិដ្ឋាការ) ឱ្យចូលរួមអនុវត្តតាមលិខិតបទដ្ឋានច្បាប់បានចំនួន៤កន្លែង នៅស្រុកក្រឡាញ់ និងស្រុកស្រីស្នំ
- បានចុះត្រួតពិនិត្យ ណែនាំ និង លើកកម្ពស់ការអនុវត្តច្បាប់ដល់អាជីវករ-សិប្បករដែលកំពុងបម្រើសេវាកម្មទាក់ទងនិងជំនាញសិល្បៈសូនរូបនិងសិល្បៈសិប្បកម្មនៅស្រុកបន្ទាយស្រី
- បានចុះត្រួតពិនិត្យទីតាំងដែលអាជីវករសុំលើកស្លាកយីហោ ផ្ទាំងផ្សាយពាណិជ្ជកម្ម និងសម្អាងការ និងបានឲ្យមកសុំច្បាប់អនុញ្ញាតពីសាលាក្រុងសៀមរាប
- បានចុះត្រួតពិនិត្យទីតាំងបង្រៀនក្បាច់គុនល្បុក្កតោ នៅសង្កាត់ក្របីរៀល ក្រុងសៀមរាប
- ការិយាល័យច្រកចេញចូលតែមួយក្រុងសៀមរាប បានផ្ដល់ច្បាប់សេវាកម្មលើវិស័យវប្បធម៌ និងវិចិត្រសិល្បៈចំនួន១១ច្បាប់

## *មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តស្ទឹងត្រែង ៖*

- បានចុះណែនាំអាជីវករជួល-លក់ថាស និងបានឲ្យយកថាសដែលមានទិដ្ឋាការមកចុះបញ្ជីបានចំនួន៥កន្លែង នៅក្រុងស្ទឹងត្រែង
- បានចុះផ្សព្វផ្សាយអនុក្រឹត្យលេខ៦៣ របស់រាជរដ្ឋាភិបាល ស្ដីពីការគ្រប់គ្រងត្រួតពិនិត្យវិស័យភាពយន្ត-វីដេអូនៅតាមហាងខារ៉ាអូខេចំនួន៧កន្លែង នៅក្រុងស្ទឹងត្រែង

- ការិយាល័យច្រកចេញចូលតែមួយ  បានផ្តល់ច្បាប់សេវាកម្មលើវិស័យវប្បធម៌ និងវិចិត្រសិល្បៈចំនួន១ច្បាប់

*__មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តស្វាយរៀង ៖__*

- បានចុះបង្ហាត់របាំដល់ក្រុមសិល្បៈមហាជនចំនួន០៣ក្រុម
- បានចុះត្រួតពិនិត្យអាជីវកម្មជួល-លក់ថាសចំនួន០៣លើក
- បានចុះផ្សព្វផ្សាយច្បាប់ពាក់ព័ន្ធវិស័យភាពយន្ត-វីដេអូចំនួន០១លើក
- បានចុះត្រួតពិនិត្យ និងឲ្យម្ចាស់សិប្បកម្មមកធ្វើច្បាប់ប្រកបអាជីវកម្មបានចំនួន០៤កន្លែង
- បានចុះត្រួតពិនិត្យការដាក់តាំងស្លាកយីហោ និងផ្ទាំងផ្សាយពាណិជ្ជកម្មចំនួន០១លើក
- ការិយាល័យច្រកចេញចូលតែមួយ  បានផ្តល់ច្បាប់សេវាកម្មលើវិស័យវប្បធម៌ និងវិចិត្រសិល្បៈចំនួន៣ច្បាប់

*__មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តឧត្តរមានជ័យ ៖__*

- បានចុះពិនិត្យបញ្ចាំងភាពយន្ត-វីដេអូ ដែលគ្មានទិដ្ឋាការពីក្រសួងវប្បធម៌ និងបានធ្វើការណែនាំដល់អាជីវករជួលមេក្រូ ធុងបាស វីដេអូចល័ត អំពីកម្រិតសម្លេង នៅស្រុកចុងកាល់
- បានចុះផ្សព្វផ្សាយ អំពីក្បាច់ចម្លាក់បុរាណ ចាក់ពុម្ពស៊ីម៉ងត៍ នៅក្នុងស្រុកអន្លង់វែង
- បានចុះទៅធ្វើបទបង្ហាញអំពីក្បាច់ចម្លាក់បុរាណ ចាក់ពុម្ពស៊ីម៉ងត៍នៅស្រុកចុងកាល់
- បានចុះពិនិត្យអាជីវកម្មអ៊ុតសក់ សម្អាងការ និងលម្អក្រចក និងចុះពិនិត្យការតាំងស្លាកយីហោផ្សាយពាណិជ្ជកម្មនៅស្រុកចុងកាល់
- បានចុះស្រាវជ្រាវពិធីជញ្ជាត់ព្រលឹងនៅក្នុងស្រុកអន្លង់វែង
- ការិយាល័យច្រកចេញចូលតែមួយក្រុងសំរោង  បានផ្តល់ច្បាប់សេវាកម្មលើវិស័យវប្បធម៌ និងវិចិត្រសិល្បៈចំនួន១ច្បាប់

### ១.២.៤. សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ

- បានបន្តអនុវត្តកម្មវិធីសិក្សាឆ្នាំសិក្សា២០១៥-២០១៦
- បានបើកបាឋកថាស្តីពី "ស្ថាបត្យកម្ម និងវិសាលភាព"
- សាស្ត្រាចារ្យ និងនិស្សិតឆ្នាំទី៣ ទី៤ ចំនួន៦២នាក់ នៃមហាវិទ្យាល័យបុរាណវិទ្យា បានចុះកម្មសិក្សារយៈពេល៥ថ្ងៃ នៅខេត្តព្រះវិហារ
- សាស្ត្រាចារ្យ និងនិស្សិតឆ្នាំទី៤ ចំនួន១៤នាក់ នៃមហាវិទ្យាល័យបុរាណវិទ្យា បានចូលរួមធ្វើកំណាយស្រាវជ្រាវឡកុលាលភាជន៍ នៅស្ថានីយជើងឯក
- ថ្នាក់ដឹកនាំ សាស្ត្រាចារ្យ និងនិស្សិតឆ្នាំទី៤ ចំនួន១២នាក់ នៃមហាវិទ្យាល័យបុរាណវិទ្យា ចូលរួមហ្វឹកហាត់វគ្គបណ្តុះបណ្តាលផ្នែករៀបចំប្លង់ និងអភិរក្សប្រាសាទបាណន់ នៅខេត្តបាត់ដំបង ដោយមានកិច្ចសហការជាមួយសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ និងសាកលវិទ្យាល័យ TOULOUSE ប្រទេសបារាំង

លទ្ធផលសកម្មភាពការងារវប្បធម៌ និងវិចិត្រសិល្បៈ ក្នុងខែឧសភា ឆ្នាំ២០១៦នេះ ជារួមឃើញថា មានដំណើរការល្អ ដោយសារស្មារតីមោះមុត ពុះពារ និងការតាំងចិត្តខ្ពស់របស់ថ្នាក់ដឹកនាំ ព្រមជាមួយការចូលរួមចំណែកយ៉ាងសកម្មរបស់មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់។ ការខិតខំប្រឹងប្រែងនេះនឹងនាំឲ្យឈានទៅសម្រេចបាននូវផែនការសកម្មភាពការងារវប្បធម៌ និងវិចិត្រសិល្បៈប្រចាំឆ្នាំ២០១៦ ហើយដែលនឹងនាំឲ្យសម្រេចបានតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិឆ្នាំ២០១៤-២០១៨ ក្នុងវិស័យវប្បធម៌ជាចុងក្រោយបង្អស់។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់។

សូម **ឯកឧត្តមបណ្ឌិតសភាចារ្យ** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ ។

**រដ្ឋមន្ត្រី**

**ចម្លងជូន៖**

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-គណៈកម្មការអប់រំ ធម្មការ វប្បធម៌ ទេសចរណ៍ ព្រឹទ្ធសភា
-គណៈកម្មការទី ៧ រដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី (នាយកដ្ឋានសរុប)
-ក្រសួងផែនការ (វិទ្យាស្ថានជាតិស្ថិតិ)
-ក្រុមសង្កេតការសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ទីស្តីការគណៈរដ្ឋមន្ត្រី)
-ឯកសារ-កាលប្បវត្តិ